# មជ្ឈមណ្ឌលឯកសារកម្ពុជា

**សម្ភាសន៍ជាមួយឈ្មោះ មិន ម៉ៃ ភេទប្រុស អាយុ៥៣ឆ្នាំ**

**មុខងារជំនាន់ខ្មែរក្រហមៈ យុទ្ធជនកងចល័ត**

**ស្រុកកំណើតៈ នៅភូមិកោះកេរ្តិ៍ ឃុំស្រយ៉ង់ ស្រុកគូលែន ខេត្តព្រះវិហារ**

**សព្វថ្ងៃរស់នៅភូមិកោះកេរ្តិ៍ ឃុំស្រយ៉ង់ ស្រុកគូលែន ខេត្តព្រះវិហារ**

**ថ្ងៃទី១៤ ខែ ឧសភា ឆ្នាំ២០១៣**

**សម្ភាសន៍ដោយ ៈ ឡុង ដានី**

**២៦ ទំព័រ**

**០០:៤៨:០២**

ដានីៈ បាទ! លោកពូមុនខ្ញុំសួរនាំលោកពូទាក់ទងពីជីវិតរបស់លោកពូ ខ្ញុំចង់ណែនាំខ្លួនប្រាប់លោកពូមួយសារទៀត ខ្ញុំឈ្មោះដានី ហើយគាត់ឈ្មោះ វណ្ណៈ ពីនាក់ខ្ញុំមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា នៅភ្នំពេញណាលោកពូៗ ហើយមជ្ឈមណ្ឌលឯកសារយើងប្រមែប្រមូលចងក្រងឯកសារក្នុងសម័យបីឆ្នាំ សម័យសង្គ្រាមអីហ្នឹងលោកពូ ហើយខ្ញុំមកជួបលោកពូនេះគឺ ចង់ដឹងពីបទពិសោធន៍ជីវិតរបស់លោកពូ តាំងពីក្មេងៗមក បាទ! ដូចថាឆ្លងកាត់មកពីរបបមួយផុតរបបមួយៗចូលរបបមួយ រហូតមកដល់បច្ចុប្បន្នយើងអភិវឌ្ឍន៍ប្រទេសយ៉ាងម៉េចខ្លះ ជីវិតរស់នៅរបស់លោកពូអីយ៉ាងម៉េចខ្លះណាលោកពូ ចឹងដំបូងខ្ញុំចង់ស្គាល់ឈ្មោះលោកពេញលោកពូឈ្មោះអីដែរលោកពូ?

ម៉ៃៈ ឈ្មោះ ម៉ៃៗ

ដានីៈ ឈ្មោះ ម៉ៃ ហ៎?

ម៉ៃៈ បាទ!

ដានីៈ ឈ្មោះ អីម៉ៃ ត្រកូលពេញ?

ម៉ៃៈ មិន!

ដានីៈ មិន ម៉ៃ ហ៎?

ម៉ៃៈ បាទ!

ដានីៈ លោកពូ អាយុប៉ុន្មានហើយសព្វថ្ងៃ?

ម៉ៃៈ ៥៣ហើយខ្ញុំៗ

ដានីៈ អាយុ៥៣! កើតឆ្នាំ១៩០០ប៉ុន្មាន?

ម៉ៃៈ ១៩៥៥ៗ

ដានី: ១៩៥៥! ស្រុកកំណើតកើតជានៅឯណាដែលលោកតា?
ម៉ែ: នៅហ្នឹងនេះឯង ។
ដានី: នៅភូមិអីគេដែរតា?
ម៉ែ: កោះកេរ្តិ៍ ឃុំស្រយ៉ង់ ស្រុកគូលែន ។
ដានី: ឃុំស្រយ៉ង់ ស្រុកគូលែន ខេត្តអ្វីដែរ?
ម៉ែ: ខេត្តព្រះវិហារ ។
ដានី: សព្វថ្ងៃនោះតានៅភូមិអីដែរ?
ម៉ែ: កោះកេរ្តិ៍ ។
ដានី: សព្វថ្ងៃរស់នៅភូមិ ឃុំដដែរ?
ម៉ែ: បាទ! ដដែរ ។
ដានី: ប៉ុន្តែកាលពីដើមកោះកេរ្តិ៍នៅក្នុង ឃុំស្រយ៉ង់ ស្រុកគូលែនចឹងតាំងពីដើមចឹង?
ម៉ែ: បាទ! តាំងពីដើមមក តាំងពី៧៩មក ។
ដានី: ចុះពីមុនហ្នឹង?
ម៉ែ: ពីមុនក៏នៅ ឃុំស្រយ៉ង់ដែរ នៅឃុំស្រយ៉ង់ដដែរនេះឯង បាទ! ៧៩មក ។
ដានី: លោកតា! គ្រួសារលោកតាឈ្មោះអីដែរ?
ម៉ែ: ឈ្មោះ ថន លាង ។
ដានី: ថន? ថន លឿន?
ម៉ែ: ថន លាង ។
ដានី: ថន លាង ។ គាត់អាយុប៉ុន្មានដែរ?
ម៉ែ: ៣៤ ហើយ ។
ដានី: តិចជាងលោកតា?
ម៉ែ: តិចជាងបើខ្ញុំ ប្រពន្ធពីរទៅហើយ ដើរទៅយកក្រោយគេបំបែក មុនប្រពន្ធខ្ញុំរត់ទៅថៃ ។ ខ្ញុំយកប្រពន្ធទៀត គេយកប្តីហើយ ខ្ញុំយកប្រពន្ធឯនេះ ។
ដានី: ប្រពន្ធមុនឈ្មោះអីដែរ?
ម៉ែ: លុន អាន ។
ដានី: គាត់អាយុប៉ុន្មានដែរ កាលគាត់នេះ?
ម៉ែ: ឆ្នាំច ប្រហែលជាសែជាង ។
ដានី: ៤០ជាង ។ បាទ! លោកតាមានកូនប៉ុន្មាននាក់ដែរ?

ម៉ែ:   កូនខ្ញុំមាន៣នាក់ទេ ។

ដានី:   កូនបីនាក់ណ៎ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ម៉ែ:   ប្រុសពីរ ស្រីមួយ ។

ដានី:   ហើយ ឪពុកលោកពូ គាត់ឈ្មោះអីដែរ?

ម៉ែ:   ឌី មិន ។

ដានី:   ឌី មិនហេ៎?

ម៉ែ:   បាទ!

ដានី:   សព្វថ្ងៃគាត់នៅឯណាដែរ?

ម៉ែ:   ស្លាប់បាត់ហើយ ។

ដានី:   ស្លាប់ហើយ ។

ម៉ែ:   ទាំងម្តាយ តាំងឪពុកអស់ហើយខ្ញុំ ។

ដានី:   ចុះម្តាយឈ្មោះអីទៅ?

ម៉ែ:   ម៉ យាន ។

ដានី:   ម៉ យាម?

ម៉ែ:   បាទ! ម៉ យាន ។

ដានី:   ម៉ យ៉ាន?

ម៉ែ:   បាទ!

ដានី:   គាត់ស្លាប់ដែរ បងប្អូនប៉ុន្មាននាក់ដែរ?

ម៉ែ:   បងប្អូន៧នាក់ ។

ដានី:   បងប្អូន៧នាក់ ។ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ម៉ែ:   ប្រុស៦ ស្រី១ ។

ដានី:   ប្រុស៦ ស្រី១! លោកពូ កូនទីប៉ុន្មានទៅ?

ម៉ែ:   កូនខ្ញុំហ៎?

ដានី:   បាទ! លោកពូទីប៉ុន្មាន?

ម៉ែ:   ខ្ញុំបងគេបង្អស់ ។

ដានី:   បងគេបង្អស់ ទីហេ៎?

ម៉ែ:   បាទ!

ដានី:   កាលពីក្មេងៗ បានរៀនសូត្រអីដល់ណាដែលលោកពូ?

ម៉ែ: ខ្ញុំរៀនដែលពីដើម ប៉ុនថានិយាយទៅពីសង្គមណា!

ដានី: បាទ!

ម៉ែ: រៀនបានបី បួនខែ ធ្វើយោធានៅប៉ុល ពតនោះ ។

ដានី: រៀនបានបី បួនខែ ចូលយោធា?

ម៉ែ: បាទ! ចូលយោធា ក៏ឈប់រៀនឈប់អី ។

ដានី: ចូលយោធា ប៉ុល ពត?

ម៉ែ: បាទ! យោធា ប៉ុល ពត ឆ្នាំ៧០ ។

ដានី: យោធាខ្មែរក្រហមឆ្នាំ៧០ ។ នៅឯណា ចូលយោធាខ្មែរក្រហមនៅឯណា?

ម៉ែ: នៅចារកន្ទួតយើង នៅតាមព្រំដែនយើង ប្រាសាទព្រះវិហារ ។

ដានី: នៅចារកន្ទួត លោកពូចូលពីហ្នឹង ឬចូលនៅនោះ?

ម៉ែ: ចូលពីនេះទៅ ដំបូង ចូលពីស្រុកយើងហ្នឹងណា បញ្ជូនទៅឯណោះឯងទៅព្រះវិហារ ។

ដានី: ចុះកាលហ្នឹង កាលជំនាន់លោកពូចូលទៅ ចូលទៅប៉ុន្មាននាក់?

ម៉ែ: ចូលច្រើនណាស់លោកគ្រូ ចូលច្រើន និយាយរួមមួយស្រុក មួយខេត្តទាំងអស់ ទៅលះបង់ ធ្វើយោធាហ្នឹងណា ។

ដានី: យោធាចារកន្ទួត នៅខេត្តព្រះវិហារដែរ?

ម៉ែ: នៅខេត្តព្រះវិហារ ។

ដានី: ជិតប្រាសាទព្រះវិហារដែរអត់?

ម៉ែ: ជិតប្រាសាទ! ទៅពីចារកន្ទួតទេ ប្រាសាទព្រះវិហារ ដើរទៅមួយថ្ងៃដែរ បានដល់ភ្នំបាទ!

ដានី: ពេលលោកពូនៅហ្នឹងធ្វើអីខ្លះទៅ?

ម៉ែ: ធ្វើអីទេលោកគ្រូ ធ្វើតែជីកប្រឡាយបិទ ទំនប់ ក្រោយពេលរំដោះហើយណា ។

ដានី: ប៉ុន្តែពីឆ្នាំ៧០?

ម៉ែ: ៧០,៧១,៧២,៧៣,៧៤,៧៥ គេរំដោះទូទាំងអ៎ ។

ដានី: ប៉ុន្តែពីឆ្នាំ៧០ លោកពូចូលធ្វើទាហាន តាំងពីឆ្នាំ ៧០?

ម៉ែ: បាទ! ធ្វើយោធា៧០ ។

ដានី: ធ្វើយោធា យោធានៅចារកន្ទួតហ្នឹង?

ម៉ែ: ចារកន្ទួតហ្នឹង ។

ដានី: នៅក្នុងកងអីគេហ្នឹង?

ម៉ែ: ហ៊ូ! ភ្លេចហើយលោកគ្រូសព្វថ្ងៃហ្នឹង ។

ដានី: សព្វថ្ងៃភ្លេចហើយណ៎?

ម៉ែ: បាទ! ភ្លេចហើយខ្ញុំ ។

ដានី: ប្រធានគេឈ្មោះអីកាលហ្នឹង?

ម៉ែ: ប្រធានក៏មិនសូវស្គាល់ដែលលោកគ្រូអើយ! ព្រោះគេដូរដាប់រហូត ។

ដានី: គេដូរចាប់រហូតហ៎កាលហ្នឹង?

ម៉ែ: បាទ! គេដូរមេៗកម្មាភិបាលណ៎! បាទ! ដូរដាក់នេះម្តងនោះម្តង ស្គាល់តែមួយភ្លែតៗភ្លេច អស់ហើយលោកគ្រូ សព្វថ្ងៃ ។

ដានី: គេហៅថាកងអីទៅនៅចារកន្ទួតកាលដំបូង? កងអនុវរសេនាធំ វរៈ?

ម៉ែ: កងវរៈ ៣៣០ ។

ដានី: នៅវរៈ ៣៣០?

ម៉ែ: គ-៣២២ ។

ដានី: បាទ? គ-៣២២ ។ វរៈ៣៣០ ,វរសេនាតូចចឹងណ៎?

ម៉ែ: បាទ!

ដានី: អត់មានកងពលវរសេនាធំអីទេ?

ម៉ែ: ទេ! មានតែវរៈតែប៉ុណ្ណោះឯង ។

ដានី: តែអត់ចាំថាប្រធានឈ្មោះអីទេលោកពូ?

ម៉ែ: ហ៊ូ! ចាំមិនទាន់ទេលោកគ្រូ ច្រើនណាស់លោកគ្រូ សព្វថ្ងៃភ្លេចភ្លាំងហើយលោកគ្រូ ។

ដានី: ពីហ្នឹងទៅចារកន្ទួតឆ្ងាយទេ?

ម៉ែ: ឆ្ងាយតាលោកគ្រូ! ដ៏ជិះម៉ូតូពីហ្នឹងទៅមួយថ្ងៃ មួយថ្ងៃដែលហ្នឹង ។

ដានី: ជិះម៉ូតូមួយថ្ងៃ?

ម៉ែ: បាទ!

ដានី: ចុះបើយើងដើរ?

ម៉ែ: អ៊ូយដើរ! រាប់ថ្ងៃហើយដើរ៥,៦ថ្ងៃ ។

ដានី: ចុះកាលជំនាន់នោះ ពេលដែលយើងចូលយោធាហើយ យើងទៅពីហ្នឹងទៅចារកន្ទួតយើងជិះ អីទៅ?

ម៉ែ: អត់មានអីទេលោកគ្រូ មានតែដើរប៉ុណ្ណោះឯង ពីដើមទៅមានឡាន មានម៉ូតូពីណា?

ដានី: ដើរទៅ?

ម៉ែ: បាទ!

ដានី:  ដើរទៅឆ្ងាយណាស់ហើយ?

ម៉ែ:  ដើរមួយថ្ងៃៗវាល់ល្ងាច ដើរសម្រាកៗចឹងឯង ទាល់តែដល់ ហើយបានគេបញ្ចូលតាមវរៈ តាម-គ ។

ដានី:  ចូលតាមវរៈ តាម-គ ។ ចុះពេលទៅដល់នោះហើយមានត្រលប់ទៅលេងផ្ទះដែរអត់?

ម៉ែ:  អត់មានច្បាប់ឲ្យទេលោកគ្រូ ។

ដានី:  អត់មានច្បាប់មកទេណ៎?

ម៉ែ:  បាទ! មានពេលច្បាប់មកលេងនរណាទុក្ខនរណា អត់បានទេ នៅតែប៉ុណ្ណោះឯង ថាបើបានទៅលេងនៅឯផ្ទះ នៅឯនោះមាន ពួតែគេថា គេយកទៅលុតដីតាមគេគ្រូជំនាន់នោះ បើពុំបត់តាមគេ វាស្លាប់ដែរហ្នឹង ។

ដានី:  ហ្ន៎ចឹងហ៎?

ម៉ែ:  បាទ! ខុសអីវាយចោលឥតស្រណោះទេកាលនោះ ។

ដានី:  ចុះលោកពូពេលដែលយើងបែកភ្នំពេញឆ្នាំ៧៥ ពេលដែលរំដោះបានហើយ ឆ្នាំ៧៥ លោកពូនៅធ្វើអីវិញទៅ? ធ្វើយោធាទៀត ឬក៏?

ម៉ែ:  ទេ! មកនៅសមរភូមិក្រោយ នៅធ្វើស្រែ ។

ដានី:  ធ្វើនៅឯណាវិញ?

ម៉ែ:  មកនៅហ្នឹងនេះឯង ធ្លាក់ខ្លួនគេថាវាយចោលតាខ្ញុំ គេថាខ្ញុំខ្មែរយេះ ។

ដានី:  ឆ្នាំ៧៥មកធ្វើស្រែនៅឯណា?

ម៉ែ:  ស្រែនៅនេះ ស្រែខ្ញុំ ស្រែខាងលិចភូមិ ។

ដានី:  ចឹងឆ្នាំ៧៥ ត្រលប់មកភូមិវិញ? ពេលដែលយើងបាយរួមណា?

ម៉ែ:  បាទ! បាយរួមដុត មកនេះបាយរួមទៀត នៅចល័តនៅស្រយ៉ង់យើងនេះ ។

ដានី:  នៅស្រយ៉ង់?

ម៉ែ:  បាទ! នៅស្រយ៉ង់ ។

ដានី:  មកធ្វើកងចល័តវិញ?

ម៉ែ:  ខាងចល័ត ធ្លាក់ខ្លួនខ្ញុំ គេយកទៅវាយចោលថាខ្ញុំវាខ្មែរយេះ តាមគេចោទថាចូលតាមខ្មែរសេ-អ៊ី-អា អីណារួចក៏ យកទៅវាយចោល យកទៅដាក់កសាងនៅលុតដីនៅនេះម្តងទៀត ។

ដានី:  នៅឯណា?

ម៉ែ:  នៅស្រយ៉ង់នេះឯង ។

ដានី:  ចឹងត្រលប់ពីចារកន្ទួតមកវិញហើយ?

ម៉ែ: ត្រលប់មកវិញហើយ! ធ្លាក់ខ្លួន គេទម្លាក់ចោល គេថាយើងខ្សែរយៈណា អត់ឲ្យចូលយោធាវិញទេ ថាគេប្រុងវាយចោល ។

ដានី: ត្រលប់មកនៅកងចល័ត ចូលកងចល័ត?

ម៉ែ: មកដល់ចូលទៅចៅហ្វាយស្រុក បិះ ថនៗ គណៈគេជំនាន់នោះ ចូលខ្លួនមកនៅកងចល័ត កសាងលត់ដំខ្លួន ទម្រាំបានប៉ុនេះលោកគ្រូអើយ! ម្ដាយខ្ញុំទៅប្រមាទម្ដងពីរដង បានសម្លាប់ចោល ប៉ុនថាអំណាចទឹកដោះម្ដាយថ្ងៃ បានរស់រានជីវិតប៉ុណ្ណេះ ទើបរួចផុតពីរបប ។

ដានី: ប៉ុន្ដែបែកឆ្នាំ៧៥ដំបូង អត់ទាន់មកណា ឬក៏មកតាំងពីឆ្នាំ៧៥ហ្នឹង?

ម៉ែ: មក៧៧ មកលោកគ្រូ ។

ដានី: ៧៧ ហេ៎ ៧៧ ត្រលប់ពីចារកន្ទួតហើយមក?

ម៉ែ: បាទ! ៧៧ធ្លាក់មក ។

ដានី: ចុះពី៧៥ ?

ម៉ែ: ៧៥ នៅឯណោះ ។

ដានី: នៅធ្វើយោធាដដែរ?

ម៉ែ: បាទ! ៧៥,៧៦ ក៏គេទម្លាក់មកវិញ ។

ដានី: នៅយោធា កាលហ្នឹងមានតួនាទីអីដែរ?

ម៉ែ: យុទ្ធជនណាលោកគ្រូ អត់មានជាកម្មាភិបាលគេទេ ជាយុទ្ធជនសុទ្ធគេបញ្ជា ប៉ុនដល់ពេលខ្ញុំគេថាខ្ញុំខ្សែរយៈក៏ឲ្យខ្ញុំមកទម្លាក់ចោល គេប្រុងវាយចោលប៉ុន!

ដានី: ប៉ុន្ដែ ពុំមែនមកភូមិយើងទេណ៎ទៅនៅស្រយ័ង?

ម៉ែ: មកបាន មកចូលម៉ែឪមួយថ្ងៃ គេហៅទៅប្រមូលដាក់ចល័តបណ្ដោយ បាទ! ខំធ្វើការទាំងយប់ទាំងថ្ងៃ ចល័តរាល់ថ្ងៃអ្នកជំរះ ជំរះ អាអ្នកកាប់រំលុងចេក កាប់ទៅ ណាអ្នក(ស្ដាប់ពុំបាន) លោកគ្រូអើយ កម្មណាស់ បាយហូបក៏ពុំគ្រាប់គ្រាន់ ក៏ពុំឆ្អែតទៀត គិតទៅពីហ្នឹង ដូចយ៉ាប់មែនទែន ខំលត់ដំ កសាងខ្លួនទម្រាំបានប៉ុណ្ណេះ ខំវេទនាទាំងខ្ញុំ បានផុតទុក្ខ បានរស់នៅសព្វថ្ងៃ ។

ដានី: កាលហ្នឹង គណៈស្រុកឈ្មោះអី?

ម៉ែ: បិះ ថន ។

ដានី: គណៈស្រុកអីគេហ្នឹង?

ម៉ែ: គណៈស្រុក ឈ្មោះ ថន ហ្នឹង ។

ដានី: គណៈស្រុកអ៎?

ម៉ែ៖ គូលែន!

ដានី៖ គូលែន?

ម៉ែ៖ បាទ!

ដានី៖ អ្នកស្រុកមកពីណា គណៈស្រុក?

ម៉ែ៖ តាមពួកគេនិយាយ ថាពួកខាងនិរតីណាលោកគ្រូ ខ្ញុំមិនសូវស្គាល់ទេ។ ខាងនិរតីដែលនិយាយថា "ឆីៗ" គេនិយាយនោះ។

ដានី៖ ចុះគណៈស្រុកមុនឈ្មោះអី?

ម៉ែ៖ គណៈស្រុកមុននៅស្រុកគូលែនយើង តា ជា ពីជំនាន់ដើម តា ហង់ណា។ ដល់ចាប់តា ហង់ទៅឡើងគណៈស្រុកថ្មីប្រធានតំបន់ថ្មីប៉ុណ្ណោះណាលោកគ្រូ តាអីនៅតំបន់វៀង នៅតំបន់វៀងមួយសារនោះ។

ដានី៖ ជំនាន់តា ហង់?

ម៉ែ៖ បាទ!

ដានី៖ ដល់ពេលគេចាប់តា ហង់ទៅ គេចាប់តា ជាទៅដែរ?

ម៉ែ៖ ចាប់ទាំងអស់។ តា ជាគេចាប់ទៅ ប-៣១(ស្តាប់ពុំបាន)។

ដានី៖ ចាប់ទៅ ប-៣១?

ម៉ែ៖ បាទ! ទៅ ប-៣១។

ដានី៖ ប-៣១ នៅឯណា?

ម៉ែ៖ នៅគល់ស្ពាន ផ្លូវទៅអន្លង់វែងនោះឯង។

ដានី៖ ផ្លូវទៅអន្លង់វែង?

ម៉ែ៖ បាទ!

ដានី៖ ស្រុកអីគេ?

ម៉ែ៖ ភូមិព្រៃស្អាកណាលោកគ្រូ។

ដានី៖ ភូមិអីគេ?

ម៉ែ៖ ភូមិព្រៃស្អាក។

ដានី៖ ព្រៃស្អាក?

ម៉ែ៖ បាទ! អាហ្នឹង ប-៣១។

ដានី៖ អាហ្នឹង ប-៣១នៅព្រៃស្អាកហ្នឹង?

ម៉ែ៖ បាទ! តា ជាគេចាប់បីហ្នឹង។

ដានី៖ តា ជាគេចាប់ពីហ្នឹង? តា ជានៅ ប-៣១?

ម៉ែ៖ គាត់នៅ ប-៣១ នៅធ្វើអីកាលនោះ នៅឯចៅហ្វាយស្រុកនៅឯណា។ ដល់ចាប់ តា ហន់ ពិបទើបស្រាវជ្រាវ។

ដានី៖ គណៈឃុំកាលនោះឈ្មោះអីទៅ?

ម៉ែ៖ គណៈឃុំនោះខ្ញុំពុំស្គាល់ទេ ចាស់ថ្មីគេដូរដោះគ្នា អ្នកធ្វើការល្អពុំល្អគេទម្លាក់។

ដានី៖ បាទ! ចុះចឹងគេចាប់តា ហន់ទៅចឹង គេចាប់តា ជាទៅដែរ?

ម៉ែ៖ បាទ! ចាប់។

ដានី៖ តា ផន មកវិញ ចុះពីណាគេគណៈតំបន់?

ម៉ែ៖ អត់ស្គាល់ទេគណៈតំបន់ ប៊ិះ ឃឹម ប៊ិះសែ។

ដានី៖ ប៊ិះ ឃឹម?

ម៉ែ៖ ប៊ិះឃឹម ប៊ិះសែ!

ដានី៖ ដល់ពេលជំនាន់ តា ផនហ្នឹងឈ្មោះ ឃឹម ឈ្មោះ សែមកវិញ។

ម៉ែ៖ បាទ! គណៈតំបន់គេនេះណា។

ដានី៖ ចឹងគេឲ្យលោកពូមកលត់ដំនៅស្រយ៉ន់ហ្នឹង?

ម៉ែ៖ មកលត់ដំ មកកសាងខ្លួននៅស្រយ៉ន់ ជាប់។

ដានី៖ ធ្វើអីខ្លះទៅនៅស្រយ៉ន់ហ្នឹង គេលត់ដំហ្នឹង?

ម៉ែ៖ ធ្វើតែ ធ្វើចម្ការជម្រះដើមឈើ ជម្រះដាំដើមចេក ជម្រះស្មៅ ដាំបន្លែដាំសៀងអី ណា ចេក ត្រាវ ដំឡូងនៅដីក្រហម ចម្ការបោះពួកយើងហ្នឹង។

ដានី៖ អត់មានធ្វើស្រែទេ?

ម៉ែ៖ អត់ទេ! ស្រែគេអ្នកធ្វើមួយឡែក ម៉ែឪ ប៉ុនកូនៗដែរ គេប្រមូលដាកលចល័តហើយលោកគ្រូ មួយសារនោះ។

ដានី៖ ធ្វើការជម្រះស្មៅដាំចេក ដាំអី?

ម៉ែ៖ បាទ! ដាក់ចេក ដាក់អំពៅ ដាក់ខ្នុរនោះណា គេធ្វើជំនាន់ខ្មែរក្រហម អើយបីសងាប់ ឆ្លងកាត់ ទម្រាំផុត បាយហូបពុំគ្រាប់គ្រាន់ទៀត។

ដានី៖ ចុះកាលជំនាន់ហ្នឹង ហូបចុកអីម៉េចទៅ?

ម៉ែ៖ ហូបចុកលោកគ្រូ ហូបតែដើម ល្ហុងយើងហ្នឹង ស្លឹកដំឡូងមីហ្នឹង។

ដានី៖ ស្លឹកដំឡូងមីអីហ្នឹង?

ម៉ែៈ បាទ! គេដិ(បបរលាយចូលគ្នា)ឲ្យយើងហូប មើមដំឡូងណាដាក់ទៅលាយបាយតិចៗ លាយបន្លែច្រើន ។

ដានីៈ ស្លឹកដំឡូង ស្លឹកអី?

ម៉ែៈ បាទ! លោកគ្រូ អើយមួយជំនាន់នោះ ។

ដានីៈ ហូបមិនឆ្អែតទេ កាលជំនាន់នោះ?

ម៉ែៈ ស្រេចតែចិត្តលោកគ្រូ មកហូបមួយប្រាវបបរទៅដិ ហូបទៅមិនបានមួយគំលៀតពោះផង វេទនាណាស់លោកគ្រូ មួយសារហ្នឹង ។

ដានីៈ ចុះកាលហ្នឹងគេមានឃើញគេយកមនុស្សទៅសម្លាប់អីដែលអត់?

ម៉ែៈ ពុថាចាប់ៗគុក មិនដឹងថាដាក់អី ចេញពីគុកវាវាយចោល ។

ដានីៈ ដាក់គុកនៅឯណា?

ម៉ែៈ គុកហ្នឹង ទៅឯណា ទៅរវៀងទៅអីឯនោះណ៎លោកគ្រូ សាលាកាលេសអណ្តូងស្វាយ ទោសធ្ងន់ៗគេវាយចោល តាមនេះខាងត្បូងភូមិ ។

ដានីៈ ដាក់គុកនៅឯណា អណ្តូងស្វាយ?

ម៉ែៈ នៅសៀមរាបប៉ុនហ្នឹងឯង ។

ដានីៈ នៅសៀមរាប?

ម៉ែៈ បាទ!

ដានីៈ ចុះម៉េចបានលោកពូដឹងថានៅសៀមរាប ធ្លាប់ទៅសៀមរាបដែរ?

ម៉ែៈ ចុះពុគេនិយាយនោះខ្ញុំដែលទៅអីលោកគ្រូ! គេនិយាយថាគុកៗស្អី ដឹងថាអណ្តូងស្វាយ កន្លែងឬស្សីនៅរវៀងនោះណ៎ នៅសាលាកាលេសនោះងាប់អស់ហើយណែនៗគេចាប់ ។

ដានីៈ ចុះកន្លែងលោកពូ កន្លែងចល័តលោកពូអីអត់ដែលឃើញគេចាប់ទេណ៎?

ម៉ែៈ អត់ទេលោកគ្រូ! ហ៎បើថានៅខ្មោចលំ គូលែនធ្លាប់យកប្រពន្ធនៅគូលែន បើថាលំឆ្អើយ ថាហ៎យកប្រពន្ធដើមវិញគេក៏ទុក ប៉ុនគេថាចិត្តដាច់នឹងអូនចាន់ណា ស្លាប់រកអូនចាន់ណា គេវាយចោលលើដីក្រហមនៅស្រយ៉ង់ហ្នឹង ។

ដានីៈ គេវាយចោល?

ម៉ែៈ គេចាយចោលទាំងប្តីទាំងប្រពន្ធ ។

ដានីៈ ហេតុអីបានចាគេវាយចោល?

ម៉ែៈ ក្បត់សីលធម៌ ។

ដានីៈ ក្បត់សីលធម៌ គាត់ខុសសីលធម៌?

ម៉ៈ បាទ!

ដានីៈ ខុសសីលធម៌ ឈ្មោះអីគេ?

ម៉ៈ ស្រី ចាន់ណា បងលំ ឈ្មោះ លំ ។ គេសួរថាម៉េច មិត្តលំ មិត្ត ឯងយកប្រពន្ធដើមវិញ ឬក៏យកមីចុង បើថាលំឯងយកមីដើមរស់ គេអត់សម្លាប់ទេ ហើយគេថាទេ ខ្ញុំស្លាប់រស់ហ្នឹងអូនចាន់ណាហ្នឹង ហើយផ្ញើឃាតសម្លាប់ម្នាក់ ។

ដានីៈ ចុះលោកពូឃើញផ្ទាល់ភ្នែកទេពេលគេចាប់យកទៅវាយចោលហ្នឹង?

ម៉ៈ ឃើញជាក់ស្តែង ។

ដានីៈ ចាន់ណាមកពីណាមក?

ម៉ៈ មិនដឹងមកពីទេលោកគ្រូ មួយសារនោះ ។

ដានីៈ អ្នក១៧មេសា?

ម៉ៈ ប្រហែលជា១៧មេសាទេដឹងយ៉ាង! (ស្តាប់ពុំបាន) នៅឯនោះឯងខ្ញុំ ។ គេឲ្យខ្ញុំទៅនៅតាមក្រុមវិញ អ្នកស្រែធម្មតា បុណ្ណោះឯង តែខ្ញុំសុខភាពវាពុំបានឈឺដើមទ្រូង ធ្លាក់ឈាម ។

ដានីៈ កាលហ្នឹងប្រធានគេឈ្មោះអីដែរ ពីជំនាន់នោះ?

ម៉ៈ តា ណឹម វរៈនៅស្រយ៉ង់ ។ តា ណឹមៗ កងចល័តនេះលោកគ្រូ ។

ដានីៈ តា ណឹតហ្នឹង ប្រធានកងចល័ត ហើយលំហ្នឹងគាត់នៅចល័តដែរ?

ម៉ៈ លំ ហ្នឹងគាត់នៅចល័តដូចអស់យើងខ្ញុំនឹងណា ។

ដានីៈ ចាន់ណាក៏ចឹងដែរ?

ម៉ៈ បាទ!

ដានីៈ មានឃើញពីណាទៀត?

ម៉ៈ អត់ទេលោកគ្រូ អស់ហើយតែប៉ុណ្ណឹងឯង តាំងពីនោះមកគ្មានឃើញនរណាចាប់ទេនរណាទេ ចាប់ៗហើយខ្ញុំវាមកនេះហើយ ផ្ទះតាខ្ទួនឯង ។

ដានីៈ បាទ! ចុះលោកពូមកនៅស្រយ៉ង់នេះរហូតដល់បែក៧៩ បណ្តោយ?

ម៉ៈ បាទ!

ដានីៈ អត់មានផ្លាស់ទៅណាទៀតទេ?

ម៉ៈ បាទ! នៅនេះរហូតទល់តាំងឆ្នាំ៧៩ រហូតដល់សព្វថ្ងៃលោកគ្រូ ។

ដានីៈ ចុះលោកពូ ដែលឃើញមុខ តា ហង់ដែរ ទេ?

ម៉ៈ តា ហង់! មុខ មិនដែលឃើញយ៉ាងណាទេ តា ហង់ ។ តា ហង់ៗ ឮតែគេថាមិនដែលឃើញទេលោកគ្រូ ។

ដានី៖ ចុះតា ដា?

ម៉ែ៖ តា ដា សុទ្ធតែនៅគូលែន ខ្ញុំស្គាល់គាត់ដែរ ។

ដានី៖ ស្គាល់គាត់ច្បាស់ដែរ?

ម៉ែ៖ បាទ! កាលមុនដែលឃើញ គាត់ធ្វើយោធាធ្វើនៅជាមួយគាត់ដែរ នៅស្រុកគូលែន ។

ដានី៖ នៅចារកន្ទុត ហ្នឹងហ៎?

ម៉ែ៖ បាទ! ដែលមុនៗ ណាលោកគ្រូ! ធ្វើនៅគូលែនប្រហែលជាកន្លះឆ្នាំ ទើបបញ្ជូនទៅនេះដើរតាមស្រុកយកបូកនឹង កម្ទាំងប្រាសាទព្រះវិហារហ្នឹង ។ ចប់ តា ដាគាត់ឃើញមុខខ្ញុំ ខ្ញុំឃើញមុខគាត់កាលនោះលោកគ្រូ ទាល់តែគាត់បាត់ជីវិត នោះឯងដែលខ្ញុំឃើញគាត់ ។

ដានី៖ ចុះជំនាន់តា ថន, តា ឃឹម, តា សែ,អី ដែលឃើញមុខទេ?

ម៉ែ៖ ចប់ហើយលោកគ្រូ មិនដែលឃើញមុខទេឮតែគេថា ។

ដានី៖ ឮតែគេថាទេ?

ម៉ែ៖ ដឹងណាឃឹម ដឹងណាសែទេ ដឹងតា អាថន ឃើញពេញមុខ ។ ថន មកចល័តស្រយ៉ង់ ប្រជុំមកចល័តស្រយ៉ង់ បងប្អូនវាប្រកាសថាធ្វើបដិវត្តន៍តែបីបួននាក់ក៏បានដែរឲ្យតែឲ្យបានអ្នកដាច់ខាត ។ បាទ! ប្រកាសនៅក្នុងកងចល័តលោកគ្រូ បាទ! ថាធ្វើបដិវត្តន៍តែបួនប្រាំនាក់បានហើយ ។ តា វង់ យើងនៅញោ គាត់ថា បានយោបល់ថា អង្គការធ្វើបដិវត្តន៍លុះត្រាប្រជាជាន មហាជនចូលរួមកុះករ បានធ្វើបដិវត្តន៍សម្រេច មិនធ្វើបដិវត្តន៍ទេ៣,៤,៥នាក់បានទេ ។ សេ-អ៊ី-អា គេប៉ុន្មានចាប់តា វង់ វឹង ។

ដានី៖ ឈ្មោះអី?

ម៉ែ៖ តា វង់ ។

ដានី៖ តា វង់ គាត់ធ្វើអី?

ម៉ែ៖ នែ៎ក ទាហានសហករណ៍ប៉ុណ្ណោះឯង តា វង់រត់ប្រុច ។

ដានី៖ ចឹង ថននោះធ្លាប់មកប្រជុំនៅកន្លែង?

ម៉ែ៖ ធ្លាប់មកស្រយ៉ង់ មកប្រកាសមកប្រជុំ ។

ដានី៖ មកប្រជុំណោស្រយ៉ង់ ស្រយ៉ង់កន្លែងឃុំគេ?

ម៉ែ៖ កន្លែងចល័ត ។

ដានី៖ កន្លែងចល័ត ។

ម៉ែ៖ នារីយុវ័នអីគេប្រុសស្រីដូចយើងទាំងអស់កងចល័ត ។

ដានី៖ គាត់ថាធ្វើបដិវត្តន៍តែ៤,៥នាក់ក៏បានដែរ?

ម៉ែះ បាទ! ធ្វើបដិវត្តន៍តែ៤,៥នាក់កបានដែរដាច់ខាត តា វង់ គាត់ថា ដល់អា ថន និយាយចប់ទៅ តា វង់ គាត់ថាខ្ញុំសូមមានយោបល់ថាបងប្អូន ក្នុងការធ្វើបដិវត្តន៍ គ្មាននរណាធ្វើបដិវត្តន៍៤,៥នាក់បានទេ។ ធ្វើបដិវត្តន៍លុះត្រាតែមហាជន ប្រជាជនចូលរួម កុះករបានធ្វើសម្រេចការកិច្ចបាន ដល់ពេលបញ្ចប់ ដល់អាគីនទាំងប៉ុន្មាននោះដៃជើងចាប់ តា វង់,តា វង់ប្រុចរត់។

ដានីះ រត់អេ៎! រត់ទៅណាទៅ?

ម៉ែះ រត់ទៅគូលែនវិញ។ ក៏បានរួចតា វង់ ទៅ។

ដានីះ បញ្ហារឲ្យឈ្មោះអី?

ម៉ែះ អាប៊ិះគីន, ប៊ិះ ម៉ានដៃស្តាំរបស់គាត់។

ដានីះ ម៉ាន ហើយនឹងយីន?

ម៉ែះ គីនៗៗ។ ម៉ាន ហើយនឹងគីន និរសារជំនិតរបស់គេណាលោកគ្រូ។

ដានីះ ចាប់តា វង់ ។

ម៉ែះ បាទ! ចាប់ តា វង់។

ដានីះ តែ តា វង់រត់រួច?

ម៉ែះ តា វង់រត់រួចចេះតែទៅ ហើយបានរស់ រស់ដល់សព្វថ្ងៃ រហូតដល់គាត់។

ដានីះ ឥឡូវគាត់នៅរស់?

ម៉ែះ ឥឡូវគាត់ស្លាប់ហើយ។

ដានីះ ស្លាប់បាត់ហើយ?

ម៉ែះ ស្លាប់បាត់៤,៥ឆ្នាំហើយ។ មនុស្ស តា វង់ គេសរសើរគាត់ ដូចបង សាំ នៅជាមេឃុំនៅសព្វថ្ងៃ គូលែនខាងត្បូងហ្នឹង គាត់ធ្វើការបានយូររបស់គាត់ណាស់ គាត់ល្អហ្នឹងអ្នកស្រុកឈ្មោះ តា វង់ៗ។ ស្រលាញ់រាប់អានណាស់ចាស់ៗ ថាកំហុសរឿងរាវ ស្លាប់ឬក៏មិនស្លាប់ក៏គាត់ដោះ ស្រាយចេញ ឬមិនចេញ។

ដានីះ គាត់ប្រធានសហករណ៍នៅឯណា?

ម៉ែះ នៅគូលែន។

ដានីះ និយាយពីការប្រជុំនៅគូលែននៅស្រយ៉ង់ គាត់ធ្វើប្រធានសហករណ៍អី?

ម៉ែះ បាទ!គេដក តា វង់ មកប្រជុំជាមួយអា ថន, អា ថន ហ្នឹងមកបានមេភូមិចឹងណា។

ដានីះ ចឹងគាត់ធ្វើគណៈស្រុកនៅជាមួយថនហ្នឹងដែរទេ?

ម៉ែះ គាត់នៅជាមួយ គូលែនហ្នឹងណា។

ដានី៖ នៅគូលែនដែរ?

ម៉ែ៖ បាទ! ជាមួយថនគេមកប្រជុំស្រយ៉ង់ តា វង់គាត់ក៏មកដែរ(ស្តាប់ពុំបាន) ។ តា គណៈៗនោះ លោកគ្រូ ។

ដានី៖ គេគណៈជាមួយ ថននោះដែរ?

ម៉ែ៖ បាទ!

ដានី៖ ប៉ុន្តែ តា វង់ មិនមែនជាអ្នកនិរតីទេ?

ម៉ែ៖ ទេ! អ្នកស្រុកស្រែធម្មតា អ្នកញៅកំបៅណាលោកគ្រូ បើអា ថន បានអ្នកនិរតីសុទ្ធពេញ សុទ្ធវាឆ្អឹង វាស្អី ។

ដានី៖ ថនហ្នឹងនៅរស់អត់ឥឡូវ?

ម៉ែ៖ ទេ! ពួគេនិយាយថានៅតាលោកគ្រូ ។

ដានី៖ នៅឯណាទៅ?

ម៉ែ៖ ខ្លះគេថានៅ ខ្លះគេថាយ៉ាងណា ខ្ញុំស្តាប់ពាក្យចុងជួនពុំបានទេលោកគ្រូ តាំពីនោះមក តាំងពី ៧៨ មកលោកគ្រូ ។ អានថន វានៅគណៈស្រុក៧៨,៧៦,៧៧,៧៨ ណាលោកគ្រូ ។

ដានី៖ ចុះលោកពូពេលបែកឆ្នាំ៧៩ ពេលវៀតណាមចូលមកវាយ៉ាងម៉េចទៅ?

ម៉ែ៖ កាលសម័យនោះៗ ខ្ញុំធ្វើតែស្រែទេលោកគ្រូទេខ្ញុំ ។

ដានី៖ ដល់ពេល៧៩មក?

ម៉ែ៖ ធ្វើតែស្រែរហូត ។

ដានី៖ ត្រលប់មកភូមិវិញ ។

ម៉ែ៖ ត្រលប់មកវិញ ។

ដានី៖ ត្រលប់មកនៅហ្នឹងវិញ?

ម៉ែ៖ បាទ!

ដានី៖ ធ្វើស្រែ កាលហ្នឹងមានប្រពន្ធនៅលោកពូ?

ម៉ែ៖ មានហើយ ។

ដានី៖ មានឆ្នាំណា?

ម៉ែ៖ មានតាំងពី៧៨ ប្រពន្ធដើមណាលោកគ្រូ ដែលថាទៅថៃ កាលជំនាន់ខ្ញុំនោះការ២៥គូ គេ (ស្តាប់ពុំបាន)ដាប់ ។

ដានី៖ ប្រពន្ធលោកពូអ្នកស្រុយកនៅឯណា?

ម៉ែ៖ នៅនេះដូចគ្នា ។ ចឹងគេទៅថៃបាត់ទៅហើយយកប្តីបាត់ទៅ ហើយខ្ញុំក៏យកប្រពន្ធទៀតសព្វថ្ងៃ ។

ដានី: លែងគ្នាយូរហើយ?

ម៉ែ: លែងយូរហើយ តាំងពីឆ្នាំ២០០៣។ គេលែងខ្ញុំរត់ទៅថៃ សុំខ្ញុំថារកស៊ីឈ្នួលនៅថៃ ហើយខ្ញុំថាឯងហើយ ដើរទៅដល់ថៃ ទៅដល់អីនៅស្រយ៉ង់មានឈ្នួលទេតើ ចាំទៅថៃមានឆ្លងប្រទេសឆ្លងអី មានទៅស្រុកខ្មែរដែលណាត្រូវឆ្លងខេត្ត ឆ្លងប្រទេសណា គេថាហ៊ឺមិននៅទេ ទៅហើយគេទៅទៅ។ ខ្ញុំថាបើទៅហើយគប្បីមាន ស្រាមួយដប ប្រាប់ចាស់ទុំមេបានេមភូមិឲ្យដឹងពុ កុំឲ្យវាខ្ញុំទៅហើយ ថាខ្ញុំកុំសង្ស័យថាជាប្តីជាប្រពន្ធនោះឯង ឯងសង្ស័យមកុំប្រាប់ថាខ្ញុំជាប្តីឯង។ លែងឲ្យដាច់គ្នាឲ្យហើយ កុំឲ្យវាកើតវាអត់សែនទៅប្រុចបាត់ហើយខ្ញុំ ដេកនៅជាមួយកូន១ឆ្នាំ គិតទៅគេទៅយកប្តីមួយទៀតបាត់ យកទៅប្រពន្ធគេ។

ដានី: ចុះពេលឆ្នាំ៧៩ហើយលោកពូត្រលប់មកធ្វើស្រែវិញរហូត ឬក៏មានចេញពីភូមិទៅណាវិញ?

ម៉ែ: អត់ទេ! លោកគ្រូខ្ញុំមិនដែលចេញទៅណាទេ។

ដានី: ពី៧៩មក?

ម៉ែ: បាទ! នៅតែផ្ទះនេះឯង។

ដានី: ពី៧៩មកនៅផ្ទះរហូត ដល់ពេលនឹង ចឹងពីជំនាន់ពេលដែលវៀតណាមចូលមកនៅភូមិនេះអីអ្នកស្រុក អ្នកភូមិនៅនេះដដែរ?

ម៉ែ: នៅនេះដដែលតាលោកគ្រូ។

ដានី: អត់មានជម្លៀសទៅណាទេ?

ម៉ែ: ទេ! អ៊ូ និយាយចឹងដូចខុសចឹងលោកគ្រូ នៅក្នុងសម័យសង្គ្រាមហ្នឹងណា ៨៣នឹងប៉ុល ពតវា៨៤ហើយ ប្រជាជននៅកោះកេរ្តិ៍ទៅនៅត្រពាំងស្វាយ។

ដានី: ៨៣ ឬ៨៤?

ម៉ែ: មកក្នុងចំនោម៨៤មកវិញ។

ដានី: ៨៣ទៅនៅត្រពាំងស្វាយ?

ម៉ែ: បាទ! ដែលប៉ុល ពតរត់។

ដានី: ទៅទាំងអស់គ្នា?

ម៉ែ: ទៅទាំងអស់មួយភូមិគេខ្លះក៏ទៅ ខ្លះក៏រត់ទៅខ្មែរក្រហមណាលោកគ្រូ។

ដានី: ចឹងអ៊ំ! ទៅត្រពាំងស្វាយនៅឯណាទៅ?

ម៉ែ: ត្រពាំងស្វាយ នៅផ្លូវស្វាយលើ យើងវៀង ត្រពាំងស្វាយ ដល់៨៤មកបាន។

ដានី: ចឹងអ្នកខ្លះទៅត្រពាំងស្វាយ អ្នកខ្លះទៅជាមួយខ្មែរក្រហម?

ម៉ៃៈ បាទ! ប្រជាជននោះនៅត្រពាំងស្វាយ ប៉ុនប្រុសៗនៅជាមួយខ្មែរក្រហម ធ្វើប៉ុល ពតណា លោកគ្រូ ។

ដានីៈ ធ្វើខ្មែរក្រហមទៅនៅឯណាទៅ?

ម៉ៃៈ ខ្មែរក្រហមនៅតាមភ្នំ ទៅអូរគ្រួច, ព្រះប្រឡាយ, អន្លង់វែងហ្នឹងណាលោកគ្រូ នៅតាមភ្នំទៅ តាមជុំវិញនឹងណាលោកគ្រូ ។ ពីឆ្នាំ៧៨នេះបានខេត្តនឹងវៀតណាមហ្នឹងយកភូមិកោះកេរ្តិ៍មក ពី ត្រពាំងស្វាយមក បានទៅនៅព្សរជ្រូក ។

ដានីៈ ចឹងឆ្នាំ៧៨ ត្រលប់មកនៅឯណាវិញ?

ម៉ៃៈ នៅកោះកេរ្តិ៍ ត្រលប់ពីកោះកេរ្តិ៍ទៅនៅព្សរជ្រូក ។

ដានីៈ ពីណាគេអ្នកយកមកកោះកេរ្តិ៍វិញ?

ម៉ៃៈ បាទ! មកពីត្រពាំងស្វាយ ។

ដានីៈ មកពីត្រពាំងស្វាយ មកនៅកោះកេរ្តិ៍ពីណាអ្នកយកមកនៅ?

ម៉ៃៈ ខេត្តណា! តាវ៉ាន ខាងពីដើមតា វ៉ាន នៅខេត្ត ។

ដានីៈ ខាងទាហាន ខាង?

ម៉ៃៈ ខាងទាហាន នរគបាលវៀតណាម យកប្រជាជនអ្នកកោះកេរ្តិ៍ពីត្រពាំងស្វាយ មកណា លោកគ្រូ ។

ដានីៈ អាជ្ញាធរអ្នកមកវិញ?

ម៉ៃៈ វៀតណាម មេយើង តា វ៉ាន ។

ដានីៈ ដឹកមកវិញ ដឹកមកវិញឆ្នាំ៧៨ មកនៅភូមិវិញ?

ម៉ៃៈ នៅភូមិហើយនៅព្សរជ្រូកលោកគ្រូ ព្រោះនៅតំបន់ហ្នឹងសុទ្ធតែខ្មែរក្រហម ។

ដានីៈ បាទ! ទៅនៅកញ្ជ្រូក? អីគេហៅអីគេ?

ម៉ៃៈ នៅព្សរជ្រូក!

ដានីៈ ព្សរជ្រូក?

ម៉ៃៈ បាទ!

ដានីៈ នៅស្រុកអីគេនៅព្សរហ្នឹង?

ម៉ៃៈ ភូមិព្សរជ្រូក ស្រុកគូលែនដែរ ។

ដានីៈ ឃុំអី?

ម៉ៃៈ នៅឃុំគូលែនខាងជើង ព្សរជ្រូក ។

ដានីៈ គូលែនជើងបាទ!

ម៉ែៈ ដល់ពេលឆ្នាំប៉ុន្មានទេមកនៅឯនេះវិញ មកនៅនេះអត់ហាននៅទេ ទៅនៅតាមព្រៃលោកគ្រូ តាមស៊ីនោះណា តាមព្រៃតាមចំការព្រៃឯណោះ នោះឯងបាន នៅកន្លែងហ្នឹងអត់ហាន នៅទេខ្លាចមីន ទាល់តែវ៉ាវបោសសំអាតអស់ហើយបានហៅអ្នកស្រុកមកនៅភូមិវិញ បាននៅជាប់សព្វថ្ងៃ ។

ដានីៈ ចឹងកាលនៅនោះ គេដាក់មីនដែលនៅតាមភូមិនេះ?

ម៉ែៈ ហ៊ឹម! ចូលប៉ុល ពតវាដាក់ វាដាក់ ប៉ះអាយ៉ង ប៉ះអីយួន ប៉ុលពតវាដាក់ណាលោកគ្រូ ។ តាមផ្លូវណាលោកគ្រូ ដើរគ្មានចូលទេលោកគ្រូ ផ្លូវនេះទៅស្រយ៉ង់យើងនេះ ទៅរំចេកសុទ្ធតែមីន ផ្លូវទៅគូលែននេះផ្លូវកាត់ទៅបេះ ។

ដានីៈ ចឹងឆ្នាំណាទៅដែលត្រលប់មកពីព្យួរជ្រូកវិញ?

ម៉ែៈ ហ៊ូដឹងឆ្នាំប៉ុន្មានទេ! ចេញពីព្យួរជ្រូកមកនៅនិងតាមភូមិ(ស្តាប់ពុំបាន) នេះបាន ។

ដានីៈ នៅឆ្នាំណា?

ម៉ែៈ បានមកនៅភូមិនេះមានមីនច្រើន ដល់ពេលក្រោយមកទៀតមិនដឹងចាឆ្នាំណាទេលោកគ្រូភ្លេចបាត់ហើយ មិនសូវចំណាំទេលោកគ្រូវាយូរហើយ ។

ដានីៈ ទៅនៅព្យួរជ្រូកមិនដឹងជាឆ្នាំប៉ុន្មានទេ?

ម៉ែៈ នៅព្យួរជ្រូកបាន២ឆ្នាំ ៣ឆ្នាំនោះ ។

ដានីៈ ២ឆ្នាំ! អាច៨៦?

ម៉ែៈ មើល៨៦,ប៉ែតអ៊ំ នៅ២ឆ្នាំនោះឯង រួចដកមកនៅឯនោះវិញ ។

ដានីៈ ប៉ុន្តែមកពីព្យួរជ្រូកមកនៅកាលហ្នឹងមនុស្សច្រើនដែរ ឬក៏អត់ទេ?

ម៉ែៈ មកដល់ទាំងអស់អ្នកភូមិលោកគ្រូ ។

ដានីៈ ចុះអ្នកដែលមកតាមខ្មែរក្រហម?

ម៉ែៈ អ្នកតាមខ្មែរក្រហមក៏ដល់ពេលចប់ផ្តាច់ខ្លួនក៏បានជួបជុំប្តីប្រពន្ធវិញ ខ្លះស្លាប់ ។

ដានីៈ ចុះអ្នកតាមខ្មែរក្រហមច្រើនតែប្រុសៗទេមើលទៅ?

ម៉ែៈ ច្រើនតែប្រុសទេ សុទ្ធតែប្រុសណ៎ា ។

ដានីៈ បាទ!

ម៉ែៈ បាទ! ស្រីខ្លះ ប្រុសខ្លះក៏ទៅក្នុង ហើយខ្លះក៏ទៅខ្មែរក្រហមទៅ ។ បាទ! ដល់ពេលក្រោយពីផ្តាច់ខ្លួនមក បានប្តីប្រពន្ធគេ មកនៅជួបជុំគ្នាវិញ ។ (ស្តាប់ពុំបាន) ។

ដានីៈ ណាផ្ទះណា?

ម៉ៃៈ នេះផ្ទះនេះពីដើម ឪវានៅព្រៃ ប្រពន្ធនៅតាមជុំរុំ(ស្តាប់ពុំបាន) ។ មិនដឹងណាណីទេលោកគ្រូ ។ នេះដូចផ្ទះមេភូមិ មេភូមិក៏នៅនេះដែរសព្វថ្ងៃ ខ្មែរក្រហម ។ ដូចកាលនៅនេះ ដូចជាឆ្នាំប៉ុន្មានទេ ដូចពុំបានជារាប់ជាចំណាំទេលោកគ្រូ គ្រាន់តែថានៅនេះថ្ងៃខែអីប៉ុន្មានមិនដឹងជាឆ្នាំប៉ុន្មាន មិនបានជាអី ។

ដានីៈ ចុះមីនអីនៅតាមស្រុកភូមិ នៅតាមផ្លូវអីអស់ឆ្នាំណា?

ម៉ៃៈ អស់ដោយសារស៊ីម៉ាក់នៅឆ្នាំ២០០០ប៉ុន្មានទេលោកគ្រូ ខ្ញុំភ្លេចអស់ហើយ ។

ដានីៈ មុនប្រពន្ធពូទៅថៃ ឬក៏ក្រោយ?

ម៉ៃៈ ប្រពន្ធខ្ញុំទៅនោះ មុនឯនេះទេ ហ៊ូក្រោយ ។

ដានីៈ ទៅឆ្នាំ២០០៣?

ម៉ៃៈ បាទ!

ដានីៈ ចឹងស៊ីម៉ាក់មកមុនឆ្នាំ២០០៣?

ម៉ៃៈ ២០០៣, ២០០៤ដែលលោកគ្រូ មកមួយសារនោះឯង ។

ដានីៈ ២០០៣,២០០៤ហើយបានដោះអស់ចឹង?

ម៉ៃៈ បាទ! បានស៊ីម៉ាក់មករ៉ាវនៅនេះអស់នៅតាមប្រាសាទ ផ្លូវជុំវិញអស់ បានលែងមានទាហាននៅនេះទៀត ហើយក៏ប្រជាជនមកនៅ គេមកនៅកោះកេរ្តិ៍នេះឯង នៅតែផ្ទះតូចៗទេពីដើម ប៉ុណ្ណោះខ្លះ! ខ្លះទៅធំជាងនោះទៅ ប្រក់ស្បូវ ដល់សព្វថ្ងៃទេបានធំ ។

ដានីៈ សព្វថ្ងៃនេះទេបានធំៗ?

ម៉ៃៈ សព្វថ្ងៃនេះធំៗណាស់ ។

ដានីៈ ចឹងប្រជាជនមក មកជុំវិញហ្នឹងពីឆ្នាំណា ដែលបានមករស់នៅជាភូមិជាអី?

ម៉ៃៈ ឆ្នាំ២០០៤,២០០៥ ជុំហើយនេះ មិនដឹងបានទៅណាទេណា មកនៅហ្នឹងទាំងអស់គ្នាមួយភ្លែតៗ គ្រាន់តែធ្វើស្រែ ។

ដានីៈ មកជុំគ្នាពីកន្លែងខ្មែរក្រហម កន្លែងផ្សេងៗមកជុំគ្នាអស់?

ម៉ៃៈ បាទ! ជុំនៅនេះទាំងអស់ ផ្តាច់ខ្លួននោះមកទាំងអស់ ទាំងប្រជាជនខ្លះក៏មក មកពីជុំរុំ តាមព្រៃតាមអីមកនៅធ្វើស្រែ កាប់ឆ្ការដំបូងៗអត់ធ្វើស្រែទេ ធ្វើតែចម្ការទេ ស្រែអត់ហ៊ានធ្វើទេស្រែ ទៅធ្វើតែចម្ការមួយកំបិចៗ ផ្ទះជិតៗគ្នា៤,៥ជុំរុំៗ ធ្វើតែចម្ការទេលោកគ្រូ អត់ធ្វើទេស្រែ កន្លែងហ្នឹង តំបន់ហ្នឹងវាមានគ្រាប់ តាមប្រាសាទតាមអីដឹងថាតែអ្នកស៊ីម៉ាក់មករក មួយថ្ងៃ៤,១០អីផ្ទុះ ។

ដានីៈ ដែលគ្រោះថ្នាក់អីដល់ប្រជាជនដែរអត់?

ម៉ែ៖ អត់ទេ!

ដានី៖ អត់មានគ្រោះថ្នាក់ទេណ៎?

ម៉ែ៖ បាទ!

ដានី៖ ចឹងអ្នកភូមិនេះ កាលពីភូមិពីមុនសម័យខ្មែរក្រហមគេប្រកបរបររកស៊ីធ្វើអីទៅ?

ម៉ែ៖ ធ្វើតែស្រែទេលោកគ្រូ ។

ដានី៖ មុនសង្គ្រាមធ្វើតែស្រែដែរ?

ម៉ែ៖ បាទ!

ដានី៖ ធ្វើស្រែហើយធ្វើអីទៀត?

ម៉ែ៖ ស្រែចម្ការនោះ មិនធ្វើអីទៀត ធ្វើតែស្រែប៉ុណ្ណោះឯង ។

ដានី៖ ចុះម្ហូបអីត្រីសាច់អី?

ម៉ែ៖ ម្ហូបគាត់ដើររកដាក់ម៉ង ដែលណាលោកគ្រូ ។

ដានី៖ ដាក់ម៉ងនៅឯណា?

ម៉ែ៖ ស្ទឹង ។

ដានី៖ ដាក់ម៉ងតាមស្ទឹង?

ម៉ែ៖ បាទ! ស្ទឹង(ស្តាប់ពុំបាន) យើងនេះឯង នៅរហាលយើងនេះឯង ផ្លូវទៅស្រយ៉ង់ ទៅនេះឆ្វេងដៃ ។

ដានី៖ ដាក់ត្រីហ៎ សម្បូរត្រីហ៎?

ម៉ែ៖ បានត្រី លួចដាក់ម៉ងទៅណា នេះហើយរបរ មិនបានទៅរកនៅឯណាឆ្ងាយ ។

ដានី៖ រកត្រីទៅ ។ ចុះសាច់អី?

ម៉ែ៖ សាច់អីរកបាន បើពីដើមមានកាំភ្លើងមានសាច់ឈ្លូស សាច់ប្រើស ។

ដានី៖ ពីមុនសម្បូរសត្វព្រៃសម្បូរ?

ម៉ែ៖ សម្បូរលោកគ្រូ ពីដើមសម្បូរចំណាប់តាមនោះ ប្រើស ខ្ទីង ទន្សង រមាំង ឈ្លូស ដល់វាក្រោយមកវាអត់មានកមាភ្លើងមានអី វាអត់ ។

ដានី៖ ឥឡូវនៅមានអត់ ឥឡូវ?

ម៉ែ៖ ឥឡូវមានតាសត្វ មាន ជ្រូក ។ ជ្រូកមានសព្វថ្ងៃ ។

ដានី៖ មានតែជ្រូកទេ?

ម៉ែ៖ បាទ! ជ្រូក ឈ្លូស ប្រើស លោកគ្រូសព្វថ្ងៃក្រ ពីដើមដីរីក៏មាននៅកោះកេរ្តិ៍នោះ ។ បាទ!ដីរីខ្ទីង ទន្សង មានតែពីរបីមុខនោះទេ សព្វថ្ងៃមានតែឈ្លូស ឈ្លូសនៅសម្បូរគ្រាន់ ។

ដានី៖ មានតែឈ្លូស ហើយនឹងជ្រូកព្រៃ?

ម៉ែ៖ បាទ! ជ្រូកព្រៃ ។

ដានី៖ នៅតាមព្រៃយើងឯក្រោយផ្ទះនឹង?

ម៉ែ៖ នៅតាមព្រៃ ។ ឲ្យតែខែកក្តិកអឹមកស៊ីស្រូវស្រែនេះ ប្រពិចនេះស៊ីស្រែ ។

ដានី៖ ចុះកាលពីមុនសម័យខ្មែរក្រហម ភូមិមានប៉ុន្មានភូមិនៅកោះកេរ្តិ៍យើងហ្នឹង?

ម៉ែ៖ មានតែកោះកេរ្តិ៍ រំចេក ។

ដានី៖ រំចេកទើបតែមានឥឡូវ ឬតាំងពីដើមមក?

ម៉ែ៖ មានផ្សារនៅកោះកេរ្តិ៍នេះលោកគ្រូ ។

ដានី៖ បាទ!

ម៉ែ៖ កោះកេរ្តិ៍ទៅ រំចក រំចេកទៅសម្បូរ សម្បូរទៅព្រៃវែង ជាប់មកទៅ ធ្លាក់ទៅបសេដ្ឋមួយ (ស្តាប់ពុំបាន) ។

ដានី៖ មានជំនាន់ណាអាហ្នឹង?

ម៉ែ៖ ជំនាន់ពីសង្គមណា៎ ។

ដានី៖ ជំនាន់ ប៉ុល ពត ឬក៏តាំងពីមុនហ្នឹងទៀត?

ម៉ែ៖ មុនប៉ុល ពតលោកគ្រូ ។

ដានី៖ មុន ប៉ុល ពតហេ៎?

ម៉ែ៖ បាទ! មុន ប៉ុល ពត សម្បូរព្រៃវែងយើងទៅណា ។

ដានី៖ ចុះប៉ុន្តែរំចេក?

ម៉ែ៖ កើតមួយសារនោះឯង ។

ដានី៖ មួយសារនោះណា?

ម៉ែ៖ មួយសារសម្បូរ ព្រៃវែងនោះណា នេះឯងភូមិ ភូមិនេះកើតក្រោយនេះទេមួយជួរស្ពឹតាមខាងលិចសម្បូរ សុទ្ធតែផ្ទះកើតក្រោយទេភូមិ បើរំចេក កោះកេរ្តិ៍ភូមិនេះកើតមុនគេប៉ុល ពតទៀត ។

ដានី៖ បើកោះកេរ្តិ៍កើតយូរហើយហេ៎?

ម៉ែ៖ យូរហើយបង លោកគ្រូ ។

ដានី៖ តាំងពីកាលមក?

ម៉ែ៖ កើតនៅឆ្នាំប៉ុន្មានទេ ខ្ញុំនៅតូចៗដែរ ស្រេចតែម៉ែឪ ។

ដានី៖ ស្រុកកំណើតម្តាយឪពុករបស់លោកពូគាត់នៅហ្នឹងដែរ ឬមកពីណាមក?

ម៉ែៈ នៅទីនេះឯងលោកគ្រូ ។

ដានីៈ នៅនេះម៉េង?

ម៉ែៈ កាលកើតនៅតូច មិនដឹងថាកើតពីឆ្នាំណាមកភូមិនេះ ស្រាប់តែកើតមកឃើញតែភូមិថាកោះកេរ្តិ៍ ។

ដានីៈ ចុះប្រាសាទនេះមានមនុស្ស មានអីមកមើលតាំងពីអន្លាល់មក?

ម៉ែៈ ប្រាសាទនេះភ្លៀវទៅមក មកតាំងពីឆ្នាំណាប៉ុន្មាន មិនចាំទេលោកគ្រូខ្ញុំ ។

ដានីៈ ចុះកាលពីជំនាន់លោកពូតូចៗ ប្រាសាទអីមានគេមកថែរក្សា មករៀបចំអីដែរអត់ កាលលោកពូនៅក្មេងៗ ។

ម៉ែៈ គ្មានណាគេមករៀបចំទេ ។

ដានីៈ លោកពូធ្លាប់ទៅមើលទេកាលពីក្មេងៗ តូចៗ?

ម៉ែៈ ទៅមើលតាប្រាសាទ ប៉ុននៅមិនពីម៉េចៗទេ ។

ដានីៈ អត់ដឹងទេណ៎?

ម៉ែៈ មិនដឹងទេ ។

ដានីៈ មានគេសំអាត ឬសុទ្ធតែព្រៃ សុទ្ធតែអី?

ម៉ែៈ ព្រៃពីដើមអត់ដូចសព្វថ្ងៃ មានស្រលះ គ្មាននរណាគេធ្វើទេ ពីដើមនោះព្រៃជិតនោះហ៊ុំតាមប្រាសាទនីមួយៗសុទ្ធតែសុងម៉ុង សុទ្ធតែព្រៃឈើធំៗ ។

ដានីៈ សុទ្ធតែព្រៃ?

ម៉ែៈ ឈើប៉ុនៗនេះឯង សព្វថ្ងៃនេះឯងដែលវាល ។

ដានីៈ មានសត្វមានអីនៅក្នុងប្រាសាទទេ?

ម៉ែៈ ដឹងទេលោកគ្រូ! ជ្រូកអីហ្នឹង នៅក្នុងកំផែងហ្នឹងជ្រូក ។

ដានីៈ ជ្រូកអី?

ម៉ែៈ ជិតណាស់លោកគ្រូ ជិតស្តុករុកមិនរួចទេពីដើមនោះបន្លាស្អីណា បន្លារនេបរនប បន្លា(ស្តាប់ពុំបាន) ហ៊ុំ ណែនប៉ែស!

ដានីៈ ណែនប៉េសតែម្តង?

ម៉ែៈ បាទ! មិនថាប្រាសាទណានៅជិតទាំងអស់ ។

ដានីៈ ចុះជំនាន់ ប៉ុល ពត?

ម៉ែៈ ជំនាន់ប៉ុល ពតមាននរណារក្សា ជិតដូចតែគ្នាដែរតា ។

ដានីៈ ទើបឆ្នាំណាដែលគេរៀបចំអី?

ម៉ៈ ពីឆ្នាំអីដែលអប្សរាមកនៅ មិនដឹងជាឆ្នាំប៉ុន្មានទេលោកគ្រូ ។

ដានីៈ ទើបអប្សរាមកនៅបានគេរៀបចំ?

ម៉ៈ បានខ្វះតាម មានកម្មករគេត្រួសបោសប្រាសសព្វថ្ងៃ ។

ដានីៈ ទើបឥឡូវៗចឹងដែរ?

ម៉ៈ ឥឡូវទេ ពីមុនមាននរណាគេបោសប្រាសទេលោកគ្រូ ដូចឈើសព្វថ្ងៃ អាធំៗអាតូចៗផង ហ្នឹងស្អេញ រកកន្លែងដើររុកមិនកើតទេ ។

ដានីៈ រកកន្លែងដើររុកពុំបានទេណ៎?

ម៉ៈ បាទ!ពីដើម ។

ដានីៈ ចុះនៅភូមិយើងមានវត្ត មានអីទេពីដើមមក?

ម៉ៈ ពីដើមមានតាវត្ត ។

ដានីៈ វត្តនៅឯណា?

ម៉ៈ វត្តនៅជិតគៀនកំផែង

ដានីៈ វត្តនៅជិតកំផែងប្រាសាទហ្នឹង?

ម៉ៈ បាទ! កំផែងប្រាសាទយើងហ្នឹង ។

ដានីៈ ចុះវត្តនោះទៅណាបាត់ហើយឥឡូវ?

ម៉ៈ អើយ! បាត់អស់ហើយសព្វថៃលោក លោកអីរត់ទៅសឹកអស់ រឿងរ៉ាវវត្តកើត ។

ដានីៈ បាទ! វត្តនោះគេរុះចោលពីអង្កាល់?

ម៉ៈ យូរហើយតាំងពីមួយសារ ប៉ុល ពតហ្នឹង ។

ដានីៈ បាទ?

ម៉ៈ ដោយសារប៉ុល ពតហ្នឹងរុះ ។

ដានីៈ ប៉ុល ពតរុះហ៎?

ម៉ៈ បាទ! រុះវត្តហ្នឹងចោលទៅ ចេញ ។

ដានីៈ បាទ! ដល់ពេលក្រោយមកទៀត ដែលយើងក៏កើតភូមិអីក្រោយឆ្នាំ៧៩មក អត់មានធ្វើវត្ត អីទេ?

ម៉ៈ អត់ទេ! អត់មានវត្តទេលោកគ្រូ ។ សាលារៀនទើបកើតថ្មីៗ ទេ២,៣ឆ្នាំមុន សាលារៀនសព្វថ្ងៃហ្នឹង ។ អាវត្តនោះទើបតែកើតទេលោកគ្រូ តាំងពីមួយសារប៉ុល ពត៣ឆ្នាំ ធ្វើវត្តធ្វើវ៉ាអី អីអត់មានទេ ពីមុននោះមានវត្តមុន រុះរើចោលអស់ហើយបាត់សាសនាកាលនោះ ។

ដានីៈ រុះរើតាំងពីឆ្នាំ ឬរុះរើពេលប៉ុល ពតចូលមក រុះរើចោលអស់ទៅ?

ម៉ែ: បាទ! រុះរើចោលអស់ទៅ។ មិនថាតែវត្តកោះកេរ្តិ៍ទេ ស្រយ៉ង់ គូលែន ក្តាក់អី ក៏រុះចោលដែរ យកអាសសរវត្តនោះធ្វើសសរល្អស សសរអីផ្ទះ។

ដានី: ហ៊ឹមចឹងហ៎?

ម៉ែ: បាទ! ប៉ុល ពតគ្រប់គ្រងលោកគ្រូហើយ ថាអត់មានសាសនាណា វាបាត់សាសនាអីបាត់អស់ហើយ កន្លែងគោរពបូជាអីគ្មានឲ្យមានទេ ថាបន់ស្រន់អីគ្មាន ពីប៉ុល ពតនាលោកគ្រូ។

ដានី: បាទ!

ម៉ែ: វាបំបាត់ វត្តអារាម លុយកាក់អស់ហើយ គ្មានអីទេ។

ដានី: ចុះលោកពូក្រោយមក ប្រជាជនយើងអត់មានធ្វើអីវិញ វត្ត ពេលទៅវត្ត ទៅវត្តនៅឯណាទេ?

ម៉ែ: វត្តស្រយ៉ង់!

ដានី: ទៅវត្តនៅស្រយ៉ង់។

ម៉ែ: ដល់ពេលបុណ្យ ដល់ពេលឡើងផ្ទះនិមន្តលោកឆាន់ និមន្តមកពីនោះឯង និមន្តពីស្រយ៉ង់។

ដានី: និមន្តពីស្រយ៉ង់មក?

ម៉ែ: បាទ!

ដានី: ចុះកាលពីជំនាន់មុនដូវអត់ល្អយើងធ្វើម៉េចទៅ?

ម៉ែ: ពីដើមមានវត្តបៀតបានទៅ មកដលសព្វថ្ងៃវាអត់មានវត្ត ទៅយកលោកមកពីវត្តគេមកដាក់។ ខស្សាហ៍មកធ្វើបុណ្យចែត្របុណ្យអី បុណ្យភ្ជុំអីនិមន្តលោកមកស្រយ៉ង់នេះឯង។

ដានី: ចុះលោកពូប្រជាជនយើងធ្វើស្អីខ្លះទៅ?

ម៉ែ: សព្វថ្ងៃនោះធ្វើតែស្រែនោះឯងលោកគ្រូ។

ដានី: ធ្វើតែស្រែទេ?

ម៉ែ: បាទ!

ដានី: ចុះបានដល បានអីហូប គ្រប់គ្រាន់ដែរអត់?

ម៉ែ: អ៊ូលោកគ្រូ ខ្លះក៏គេបានសល់ ខ្លះគ្នាខ្វះទេ គ្មានបានអីទេសព្វថ្ងៃ។

ដានី: ចុះបើយើងប្រៀធៀបពីមសម័យមុន សម័យមុនសង្គ្រាម សម័យសង្គ្រាមមកដល់ឥឡូវវាយ៉ាងម៉េចដែរ? ខុសគ្នាយ៉ាងម៉េចដែរ?

ម៉ែ: ទេអាហ្នឹងវាខុសគ្នាលោកគ្រូ កាលពីមុនសម័យសង្គ្រាមវាមានកម្ម វាលំបាកគេចតែគ្រាប់ពួនហ្នឹងគ្រាប់បាទ! ដល់សព្វថ្ងៃនេះវាស្រួល វាខុសប្លែកពីមុន មកដល់ប៉ុនេះសព្វថ្ងៃហ្នឹង

បានហូបគ្រប់គ្រាន់ មានសាច់គ្រាប់គ្រាន់ មានត្រី មានបន្លែ មានបង្គារ វាពីមុនកម្មចេះឯង កម្មឆ្អឹងកាត់ ។

ដានី៖ កាត់សង្គ្រាម?

ម៉ៃ៖ បាទ!

ដានី៖ ចុះកាលពីមុនសង្គ្រាម? កាលពីជំនាន់លោកតាពូនៅតូចៗណា?

ម៉ៃ៖ វាធូរដូចយើងសព្វថ្ងៃនេះឯង វារករបរអាជីវកម្មនោះមានជ័រទឹក មានរកប៉ក់ រកបិចដូចសព្វថ្ងៃ រកបិះបក់លក់ ព្រិច ។

ដានី៖ លក់ព្រិចលក់អី?

ម៉ៃ៖ ហ្នឹងហើយស្រីៗ ។

ដានី៖ ឥឡូវហ្នឹងហេ៎?

ម៉ៃ៖ ឥឡូវហ្នឹង ។

ដានី៖ រកអីគេ ប៉ក់ម៉េច?

ម៉ៃ៖ ប៉ក់ ព្រិច បេះប៉ក់ បេះព្រិចរួចទៅគេទិញដែរ មួយគីឡូ៣,៤៣ន់ៗ ប៉ក់ មួយគីឡូ ១៥០០ ០ ។

ដានី៖ ប៉ក់ហ្នឹងស្អីគេ?

ម៉ៃ៖ ផ្សិត ។

ដានី៖ ផ្សិតហេ៎?

ម៉ៃ៖ បាទ! ផ្សិត

ដានី៖ អាហ្នឹងម៉េចថ្ងៃម្ល៉េះ?

ម៉ៃ៖ ថ្លៃតាលោកគ្រូ អាហ្នឹងទិញ ប៉ក់ផ្សិតនោះប៉ុនៗមេដៃដែលហ្នឹងលោកគ្រូ ប៉ុនគេថាដាក់ខ្ទាញ់ ដាក់សាច់ជ្រូកទៅឆ្ងាញ់ វាជាតិ ប៉ក់ហ្នឹង ។

ដានី៖ ប៉ក់ហ្នឹង?

ម៉ៃ៖ បាទ! សព្វថ្ងៃនេះនៅរកនឹងឯង?

ដានី៖ នៅរកហេ៎?

ម៉ៃ៖ បាទ!ស្រីៗ ។ ប្រពន្ធយើងប្រពន្ធគេទៅដើរទៅរកប៉ក់ ខ្លះក៏មួយគីឡូ ខ្លះក៏បានមួយគីឡូ (ស្តាប់ពុំបាន) លោកគ្រូ ។ ស្រាប់តែដល់ប៉ុនមេជើង ប៉ុនមេដៃអីទៅ ខ្លះតូចប៉ុនៗណោះ ស្តួរៗ ទេផ្សិតហ្នឹងឯង ។

ដានី៖ អាហ្នឹងឆ្ងាញ់ហេ៎?

ម៉ៃៈ  បាទ! ឆ្ងាញ់ណាលោកគ្រូ បើថាដាក់មានសាច់ជ្រូកអីដាក់ ឆ្ងាញ់ទៅណាស់ចំណាប់ អត់ដូចផ្សិតឯទៀត ។

ដានីៈ  ចុះលោកពូមានដីស្រែអីច្រើនទេ?

ម៉ៃៈ  ខ្ញុំមានតែ២ហាត់ទេលោកគ្រូ ។

ដានីៈ  មានតែ២ហាត់ទេណ៎?

ម៉ៃៈ  បាទ!

ដានីៈ  គ្រាប់គ្រាន់អត់ប៉ុណ្ណឹង?

ម៉ៃៈ  គ្រប់ៗតាលោកគ្រូ មួយឆ្នាំបានសល់មួយ(ស្តាប់ពុំបាន) ដល់កក្តិកលក់ផងខាងនេះ ។

ដានីៈ  ចុះលោកពូ ខាងអាជ្ញាធរអេបស្រាគេអភិឌ្ឍន៍អីខាងប្រាសាទកោះអីនោះមានប៉ះពាល់អីដល់គ្រួសារលោកពូ ឬក៏អ្នកភូមិអីដែរទេ?

ម៉ៃៈ  ប៉ះពាល់នោះវាប៉ះហើយលោកគ្រូដូចថា អារឿងដីធ្លីវាមិនបាន គេមិនឲ្យពង្រីកហ្នឹងណា ។

ដានីៈ  គេមិនឲ្យពង្រីក?

ម៉ៃៈ  បាទ! ប៉ុន្តែយើងក្នុងគ្រួសារមួយ ហើយដីកំណត់នៅក្នុង៩ហិចតាម្នាក់ហូបចុកនោះតាមសព្វថ្ងៃ ចុះបើស្រែយើងថាតែ២ហិចតាហើយកូនច្រើន ហើយកាប់គាស់អី អត់ឲ្យទេ ពួកអប្សរាណាលោកគ្រូ មិនឲ្យធ្វើទេ មានដីត្រង់ណាមិនឲ្យឯងរីកទេ ។

ដានីៈ  មិនឲ្យរីកទេណ៎?

ម៉ៃៈ  បាទ!

ដានីៈ  ដីប៉ុណ្ណានៅប៉ុណ្ណឹង?

ម៉ៃៈ  បាទ!

ដានីៈ  ចុះផ្ទះសម្បែងអី?

ម៉ៃៈ  ផ្ទះសម្បែង បានលើកបានដូចថា ។

ដានីៈ  ចឹងចុះការអភិវឌ្ឍន៍របស់អាជ្ញាធរអេបស្រាហ្នឹងថាអ្នកស្រុកភូមិយើងអត់អាចពានដី ឬក៏ធ្វើផ្ទះថ្មីបានទេណ៎?

ម៉ៃៈ  បាទ!

ដានីៈ  តើចុះប្រជាជនគាត់សប្បាយចិត្ត ឬក៏មិនសប្បាយចិត្ត?

ម៉ៃៈ  ទេ! លោកគ្រូអើយរឿងសព្វថ្ងៃហ្នឹង ផ្ទះធំហើយបានសប្បាយចិត្ត បើលើកបានហើយ បើថាដូចរឿងដីធ្លីហ្នឹងគឺដូចខ្ញុំថាដី៩ហាត់ ខ្វះអត់បាន៩ទេ ខ្វះអត់មានដី បាទ! ហើយធ្វើហែកគាស់

កាស់ឆ្ការទោអត់បានចេះឯង បាទ!ខ្លះក៏វាមានហូបចុកធូរ ខ្លះក៏អត់តាំងពីប្រាំងទៅហើយ ដល់ខែវស្សារីតតែអត់ចំណាប់ គេអ្នកធូរៗ អ្នកតឹងគ្នាកំសត់លំបាកគាត់ ។

ដានី: ចុះ បាទ! លោកពូខ្ញុំដូចជាសអស់សំនួរអីហើយ ត្រូវសួរនាំលោកពូទៀតហើយចឹងលោកពូមានសំណូមពរអី ឬក៏មានអីចង់បន្ថែមទេ ទាក់ទងពីអ្វីដែលខ្ញុំបានសួរ?

ម៉ែ: គ្មានអីក្រៅពីចង់បានអណ្តូងស្នប់ សាលារៀន ផ្លូវនោះឯង ។

ដានី: បាទ! សំណូមចង់បានអណ្តូងស្នប់ ហើយហ្នឹងផ្លូវហោ៎?

ម៉ែ: បាទ!

ដានី: ផ្លូវគេកុំពុងធ្វើនេះមែន?

ម៉ែ: កុំពុងធ្វើ(ស្តាប់ពុំបាន) ។

ដានី: លោកពូ លោកពូដែលឮពីតុលាការដែលកាត់ទោសមេដឹងនាំជាន់ខ្ពស់ខ្មែរក្រហមអីដែរអត់ទេ?

ម៉ែ: ទេ! ខ្ញុំមិនស្តាប់ ស្តាប់មិនចាំទេលោកគ្រូ ។

ដានី: ប៉ុន្តែដឹងដែរអត់?

ម៉ែ: នៅតែគេផ្ទះ ស្តាប់មិនសូវដឹងទេ មិនសូវបានស្តាប់វិទ្យុទេលោកគ្រូរាល់ថ្ងៃ ។

ដានី: ប៉ុន្តែមានដឹងថានៅភ្នំពេញរាល់ថ្ងៃកាត់ទោសអីដែរអត់?

ម៉ែ: អត់ទេលោកគ្រូ អត់ដឹងទេ ។

ដានី: អត់ដឹងទេណ៎?

ម៉ែ: បាទ!

ដានី: តើលោកពូ លោកពូយល់យ៉ាងម៉េចដែរ ពេលគេកាត់ទោសមេដឹកនាំជាន់ខ្ពស់សម័យខ្មែរក្រហមអីហ្នឹង?

ម៉ែ: មិនដឹងជាយល់ឃើញយ៉ាងម៉េចទេបើសុទ្ធតែកាត់ទោសៗ ពុំសូវដឹងដែរ ។

ដានី: អត់សូវដឹងទេ?

ម៉ែ: បាទ!

ដានី: ពូអត់សូវចាប់អារម្មណ៍ទេ?

ម៉ែ: ទេ! ធម្មតាប៉ុណ្ណោះឯង ដូចថាកាត់ទោសៗចឹង ថាកាត់ពុំសូវដឹងទេលោកគ្រូ ។

ដានី: បាទៗ ចឹងលោកពូ ខ្ញុំអគុណលោកពូច្រើនដែលចំណាយពេលផ្តល់បទសសំភាសន៍ ទាក់ទងជាមួយខ្ញុំទាក់ទងពីជីវិតរបស់លោកពូណា៎ ។

ម៉ែ: បាទ!

ដានី: អគុណច្រើនលោកពូ ។ **«ចប់»**